# ភីមបុរៈ

ស្ថាននាម "**ភីមបុរៈ**" ពុំទាន់មានអ្នកសិក្សានិងអ្នកស្រាវជ្រាវជំនាន់មុន លើកយកមកជជែកពិភាក្សាឱ្យបានវែងឆ្ងាយ និងដាច់ស្រេចនៅឡើយទេ។ អ្នកស្រាវជ្រាវមួយចំនួនយល់ស្របតាមលោក អេត្យេន អៃម៉ូនីញេរ[១] ថា "**ភីមបុរៈ**" នេះត្រូវនឹងទីតាំងរបស់ប្រាសាទភិម៉ាយ ដែលជាកន្លែងកំណើតនៃសន្តតិវង្ស "**មហីធរបុរៈ**" (ឧទា. អួន ភគិនី 1998, p. 39; Chandler 1979, p. 60; Jacobsen 2008, pp. 43, 56)។ ទំនងជាលោក អេត្យេន អៃម៉ូនីញេរ យល់ថាពាក្យ "**ភិម៉ាយ**" ឬ "**ភិម៉ែ**" នេះជាពាក្យដូចគ្នាជាមួយ "**ភីម**" ទេដឹង? យ៉ាងនេះក្តីលោកបានប្រើពាក្យត្រឹមតែ "ប្រហែល"(peut-être)ប៉ុណ្ណោះ ពុំមែនជាការសន្និដ្ឋានដាច់ណាត់របស់លោកឡើយ។ បើយោងតាមសិលាចារឹកនៅប្រាសាទភិម៉ាយ K.397 គេបានស្គាល់ច្បាស់ហើយថាតំបន់ប្រាសាទភិម៉ាយនោះមានឈ្មោះបុរាណជា "**វិមាយ**"។ ចំណែកឯសិលាចារឹកសំស្រ្កឹតនៅប្រាសាទព្រះខ័ន K.908 ហៅទីនោះថា "**វិមាយបុរៈ**" ឬហៅតាមពាក្យទំនើប "**ក្រុងភិម៉ាយ**"។ បើផ្អែកតាមទិដ្ឋភាពភាសាវិទ្យា ព្យញ្ជនៈ /វ/ ពីបុរាណមានការប្រែប្រួលជា /ព/ នាពេលបច្ចុប្បន្ន។ ព្យញ្ជនៈ /ព/ នេះក៏ប្រែប្រួលជាព្យញ្ជនៈ /ភ/ ផងដែរ។ ឧទាហរណ៍ **វិមាន > ពិមាន > ភិមាន**។ នៅក្នុងភាសាខ្មែរ ការប្រែប្រួលពាក្យ "**វិមាយ**" ក្លាយជា "**ពិមាយ**" និង "**ភិមាយ**"(ឬជាភិម៉ាយ) ពុំមានអ្វីជាការចម្លែកនោះទេ។ ដូច្នេះហើយ ពាក្យ "**ភិម៉ាយ**" គឺពុំជាប់ទាក់ទងនឹងពាក្យ "**ភីម**" ដែលជាហេតុអាចនាំឱ្យយើងអាចយល់ថា **ភិម៉ាយ**" ជា "**ភីមបុរៈ**" នោះទេ។ នៅក្នុងអត្ថបទនេះ យើងសន្និដ្ឋានថា "**ភីមបុរៈ**" នៅក្នុងសិលាចារឹកសម័យមុនអង្គរ និងអង្គរ គឺត្រូវគ្នានឹងផ្នែកខ្លះនៃខេត្តបាត់ដំបងសព្វថ្ងៃ។

នៅសម័យមុនអង្គរ យើងសង្កេតឃើញស្ថាននាម "**ភីមបុរៈ**" លេចឡើងនៅក្នុងសិលាចារឹកចំនួនបី។ ទីមួយ គឺសិលាចារឹកក្តីអង្គ K.56 នៅខេត្តព្រៃវែង ដែលនិយាយអំពីការកសាងប្រតិមាក្នុងនិកាយព្រះវិស្ណុមួយអង្គនៅប្រាសាទអស្វសពោនាថ និងព្រះកាយកាត្យាយិនីដ៏ស្រស់ស្អាតមួយអង្គនៅភីមបុរៈ។[២] ទីពីរ គឺសិលាចារឹកភ្នំខៅណាយ (K.1150) ស្ថិតនៅក្នុងស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ជាសិលាចារឹកដែលដាច់សេចក្តីដោយអន្ទើ ប៉ុន្តែយើងឃើញមានស្ថាននាមនេះនៅជាមួយស្ថាននាម "**ចន្ទ្របុរៈ**"។ ចំណុចត្រង់នេះ យើងជឿថា "**ភីមបុរៈ**" មានព្រំទល់ជាប់ "**ចន្ទ្របុរៈ**" តាំងពីសម័យមុនអង្គររហូតមកដល់សម័យអង្គរ។ ទីបី គឺនៅក្នុងសិលាចារឹកភូមិដូងនេះតែម្តង។ សិលាចារឹកទាំងបីដែល

[១] Aymonier, 1901: 118

[២] Coedès 1964

**បានលើកមកបង្ហាញនេះ ពុំមានបញ្ជាក់ព័ត៌មានអំពីទំហំវិសាលភាពឬប្រភេទដែនដីរដ្ឋបាល** របស់ភីមបុរៈ ដូចសិលាចារឹកដែលប្រទះឃើញក្នុងសម័យអង្គរឡើយ។

ចំណែកនៅសម័យអង្គរវិញ យើងក៏ឃើញមានស្ថាននាមនេះនៅក្នុងសិលាចារឹកយ៉ាងហោចណាស់១0ដង ទាំងក្នុងសិលាចារឹកភាសាខ្មែរបុរាណ និងភាសាសំស្ក្រឹត។ យោងតាមសិលាចារឹកទាំងនោះ "**ភីមបុរៈ**" ជាស្ថាននាមមានវិសាលភាពដែនដីរដ្ឋបាលជា "**ប្រមាន**" (K.186: 4, K.206: 20, K.257: 41, K.270: 14), ជា "**វិស័យ**" (K.205: 38, K.938: A16) និងជា "**ព្រះស្រុក**" (K. 276: 23)។[៣] សិលាចារឹកប្រាសាទតាកែវ K.276 ដែលចារនៅសតវត្សទី១១ បានបញ្ជាក់ច្បាស់ថា "**គម្តែងជគតស្រីនរេន្ទ្រគ្រាម**"(តំបន់ប្រាសាទឯកភ្នំ)[៤] គឺស្ថិតនៅក្នុងព្រះស្រុកភីមបុរៈ។ សិលាចារឹកនេះអាចបានបញ្ជាក់ថា ទឹកដីភីមបុរៈនៅសម័យអង្គរគ្របដណ្តប់មួយផ្នែកនៃខេត្តបាត់ដំបង ត្រង់តំបន់ព្រៃកនរិន្ទ និងប្រាសាទឯកភ្នំ ស្រុកឯកភ្នំ។ លោក ដូមីនីក ហ្គូដល បានលើកឡើងថាឈ្មោះ "**ភីមបុរៈ**" ដែលបានបង្ហាញតាមរយៈសិលាចារឹកមួយចំនួននៅសម័យអង្គរនេះ អាចមានទីតាំងរដ្ឋបាលនៅកន្លែងផ្សេងគ្នា ប៉ុន្តែមានឈ្មោះដូចគ្នា។[៥] លោកក៏បានចោទជាសំណួរថាតើធ្វើដូចម្តេច ដើម្បីដឹងថាឈ្មោះនៅក្នុងសិលាចារឹកផ្សេងៗគ្នានោះសំដៅដល់ទីក្រុងតែមួយ? បើយើងត្រឡប់មកមើលសិលា-ចារឹកភូមិដូងនេះវិញ នៅសម័យមុនអង្គរ ទឹកដីភីមបុរៈ យ៉ាងហោចណាស់ក៏ត្រូវរាប់ចាប់ពីតំបន់ភ្នំបាណន់មក។ នៅទីនោះទំនងជាទីប្រជុំជននាសម័យមុនអង្គរតែម្តង ដ្បិតគេរក

[៣] «ប្រមាន» (ប្រមានិ) គឺជាបំណែងចែកដែនដីរដ្ឋបាល ឬទឹកដីធំៗ ឬភូមិភាគមួយនៃប្រទេសកម្ពុជានាសម័យបុរាណ(ឡុង សៀម, ១៩៩៧, ទំ. ១៨)។ ចំណែក «វិស័យ»(វិមយ) ក៏ជាដែនរដ្ឋបាលសម័យបុរាណដែលជាបំណែងចែកទឹកដីរាជការ សម្គាល់នូវទីរួមខេត្តដែលក្នុងនោះមានស្ថាប័នរាជការផ្សេងៗខាងគ្រហស្ថ និងសាសនា (ឡុង សៀម, ១៩៩៧, ទំ. ២១) ចំណែកឯលោក ហ្សក៍ សឺដេស (Coedès, 1951, p. 11) ប្រែពាក្យ «វិស័យ» ថា «district»(ស្រុក)។ ចំណែក «ព្រះស្រុក»(វ្រះស្រុក៑) វិញ គឺសម្គាល់ដល់ទីតាំងដីភូមិរបស់ប្រាសាទ ឬទេពអង្គណាមួយ។ ចំណែកនៅក្នុងសិលាចារឹកផ្នែកភាសាសំស្ក្រឹតវិញ យើងប្រទះឃើញហៅ «ភីមបុរៈ» ជា «វិស័យ» ឯនៅក្នុងសិលាចារឹកភាសាខ្មែរបុរាណវិញ ភាគច្រើនហៅ «ភីមបុរ» ថាជា «ប្រមាន» និងមានចំនួនតិចតួចដែលហៅជា «វិស័យ»។ យើងពិបាកបែងចែកឱ្យដាច់ណាត់ពីភាពខុសប្លែកគ្នារវាង «ប្រមាន» និង «វិស័យ» ណាស់។

[៤]នៅក្នុងសិលាចារឹកប្រាសាទឯកភ្នំ (K.211) បានបញ្ជាក់យ៉ាងច្បាស់ថាប្រាសាទសិវលិង្គនេះគឺស្ថិតនៅក្នុង « នរេន្ទ្រគ្រាម»។ ស្ថាននាមនេះនៅបន្តប្រើរហូតមកដល់បច្ចុប្បន្នក្លាយជា «នរិន្ទ» គឺជាឈ្មោះព្រៃកមួយនៅក្បែរប្រាសាទឯកភ្នំ។

[៥] Goodall 2019

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ឃើញកស្តុតាងបុរាណវិទ្យា ជាទួលប្រាសាទនាសម័យមុនអង្គរចំនួនពីរនៅទីនោះផងដែរ។ បើតាមលោក ឌី កែវ មន្ត្រីមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ ខេត្តបាត់ដំបង បានរៀបរាប់ថានៅទីតាំងរកឃើញសិលាចារឹ95%នៅភូមិដូងនោះ មានសំណល់ឥដ្ឋរាយប៉ាយ និងសម្ភារៈសំណង់ប្រាសាទមួយចំនួនផង។ រីឯលោកបណ្ឌិត ហេង ពិភាល់ បានលើកឡើងថា នៅក្នុងកំឡុងឆ្នាំ១៩៩៩ លោកបានប្រទះឃើញបំណែកផ្តែររចនាបថសំបូរព្រៃគុកនៅទីនោះផងដែរ។[៦] ចំណែកឯលោកសាស្ត្រាចារ្យ កង្វល់ គដ្ឋិមា[៧] បានប្រទះឃើញបំណែកសសរផ្អោបប្រាសាទសម័យមុនអង្គរ នៅក្នុងចម្ការទំពាំងបាយជូរមួយកន្លែង ក្បែរភ្នំបាណន់ផងដែរ។ បើពិនិត្យមើលភស្តុតាងសិលាចារឹក ដែលរកឃើញនៅភូមិដូង K.1259 វិញ ឃើញថាវាជាកំណត់ត្រាបញ្ជីអ្នកបម្រើប្រុសស្រីរបស់ "**កុរាកភីមបុរ**" ឬ "**អភិបាលភីមបុរៈ**" ដែលបានថ្វាយចំពោះប្រាសាទ "**ស្រីប្រភាសសោមេស្វរ**"។ អ្នកបម្រើទាំងនោះ មាននាទីជាអ្នកបម្រើនៅធ្វាប្រាសាទ ជាមនុស្សប្រុសចំនួន២៤នាក់ អ្នកបម្រើក្នុងប្រាសាទចំនួន២៧នាក់ (មិនបញ្ជាក់ភេទ) និងអ្នកធ្វើស្រែជាមនុស្សប្រុសចំនួន៣១នាក់ មនុស្សស្រីនិងកូន៦៨នាក់។ ផ្នែកទី២ ជាអ្នកបម្រើស្រីម្នាក់និងកូន២នាក់ ដែលជាជង្វាយរបស់ "**ម្រតាញជយោទ្វល**" ឱ្យដល់ក្រុមសិល្បករ ឬក្រុមជាង ដើម្បីបម្រើព្រះជំនួសខ្លួនគាត់។[៨] ដូច្នេះទាំងទំហំប្រាសាទនៅភូមិដូងទាំងពីរ ទាំងចំនួនអ្នកបម្រើប្រាសាទដែលកត់ត្រានៅក្នុងសិលាចារឹក គឺបង្ហាញពីវិសាលភាពតំបន់នោះ ដែលអាចមានមនុស្សរស់នៅច្រើនកុះករផងដែរ។ ឯទីតាំងប្រាសាទភ្នំបាណន់វិញ ក៏ធ្លាប់រកឃើញសិលាចារឹក និងភស្តុតាងបុរាណវិទ្យាតាំងពីសតវត្សទី១០ មុនប្រាសាទដែលសាងក្នុងរាជ្យព្រះបាទជ័យវម៌្មទី៧ផងដែរ។ ទាំងនេះសុទ្ធតែបានបង្ហាញពីចំណាស់នៃទីតាំងតំបន់នេះ។

តាមការផ្ទៀងផ្ទាត់ទិន្នន័យសិលាចារឹក "**ភីមបុរៈ**" មានទីតាំងខុសពីការសន្និដ្ឋានរបស់លោក អៃម៉ូនីញ៉េរ ដែលយល់ថាស្ថាននាម "**ភីមបុរៈ**" ពីបុរាណត្រូវនឹងតំបន់ប្រាសាទ "**ភិម៉ាយ**" ដ្បិតយើងរកឃើញភស្តុតាង ដែលគួរឱ្យជឿជាក់បានហើយថាត្រូវគ្នានឹងខេត្តបាត់ដំបងបច្ចុប្បន្ន មានទីប្រជុំជននៅតំបន់ប្រាសាទបាណន់។ ចាប់ពីសម័យមុនអង្គររហូតដល់សម័យអង្គរ វិសាលភាពរបស់"**ភីមបុរៈ**" យ៉ាងហោចណាស់គួរតែមានទំហំគ្របដណ្តប់ពីតំបន់ភ្នំបាណន់(រាប់ទាំងតំបន់ប្រាសាទស្នឹង) តាមបណ្តោយដងស្ទឹងសង្កែរហូត

---

[៦] កិច្ចសន្ទនា ខែធ្នូ ឆ្នាំ២០១៩

[៧] សូមមើល https://www.facebook.com/permalink.php?story_fbid=10155168597143446&id=721983445

[៨] ហ៊ុន ឈុនតេង ២០១៩:៥៥-៧៩

*មកដល់តំបន់ប្រាសាទឯកភ្នំ និងអាចបន្តរហូតដល់តំបន់បាក់ព្រាផងដែរ។ “**ភីមបុរៈ**” មានព្រំប្រទល់ខាងជើងឆៀងពាយព្យជាប់ “**អមោឃបុរៈ**” យ៉ាងហោចណាស់ក៏មានព្រំប្រទល់ជាប់គ្នាមណ្ឌលបុរៈដែលជាដែនដីចំណុះឱ្យភីមបុរៈផងដែរ។ នៅប៉ែកខាងត្បូងឆៀងនិរតីមួយផ្នែកគឺជាប់ជាមួយ “**ចន្ទ្របុរៈ**” ឯខាងអាគ្នេយ៍វិញ យើងហាក់ដូចជាពុំមានភស្តុតាងអ្វីអាចលើកយកមកបញ្ជាក់បាននោះទេ។*

# បញ្ជីរូបភាព





សំណល់វត្ថុសិល្បៈលម្អប្រាសាទនិងឥដ្ឋប្រាសាទនៅទួលភូមិដូង១ (រូបថត៖ https://cisark.mcfa.gov.kh)





សំណល់ថ្មទ្រនាប់កាំជណ្ដើរនិងឥដ្ឋប្រាសាទនៅទួលភូមិដូង២ (រូបថត៖ https://cisark.mcfa.gov.kh)



បំណែកសសរផ្ដោបសម័យមុនអង្គរនៅក្នុងចម្ការទំពាំងបាយជូរក្បែរជើងភ្នំបាណន់
(រូបថត៖ កង្វល់ គង្គិមា)

អត្ថបទដោយ៖ ហ៊ិន ឈុនតេង




ផែនទីសន្និដ្ឋានវិសាលភាពភីមបុរៈ កែសម្រួលពី៖ (Aymonier, 1999)



អត្ថបទចម្លងសិលាចារឹកភូមិដូង K.1259

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## ឯកសារយោង

ហ៊ុន ឈុនតេង.

២០១៩. សិលាចារឹកភូមិដូង K.1259. *កម្ពុជសុរិយា*. លេខ២ ទំព័រ៥៥-៧៩

ឡុងសៀម.

១៩៩៧. ស្ថាននាមវិទ្យាខ្មែរ (ពុទ្ធសាសនបណ្ឌិត្យ). ខ្មែរអន្តរជាតិ.

អ៊ឹន ភគិនី.

តុលា-ធ្នូ១៩៩៨. សិលាចារឹកភូមិដូង. *អក្សរសាស្ត្រ-មនុស្សសាស្ត្រ*, ទំព័រ៣៩-៤៣

Aymonier, E.

(1901). Le Cambodge, Vol. II: Vol. II. EFEO.

Coedès, G.

(1951). Inscriptions de Vat Baset (K. 205—207). In Inscriptions du Cambodge (vol. III) (EFEO, Vol. 3).

Coedès, G.

(1964). Stèle brisée de Kdĕi Aṅ (K. 56). In Inscriptioins du Cambodge (vol. III) (EFEO, Vol. 7).

Goodall, D.

(2019). Nobles, bureaucrats or strongmen? On the “vassal kings” or “hereditary governors” of pre-Angkorian city-states: Two Sanskrit inscriptions of Vidyāviśeṣa, seventh-century governor of Tamandarapura (k. 1235 and k. 604), and an inscription of Śivadatta (k. 1150), previously considered a son of Īśānavarman I. Yosothor, 14, 23–85.